# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានអនុញ្ញាតអោយ ឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសម និងជម្រាបលា

នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសមនិងជម្រាបលា បន្ទាប់ពីឯកឧត្តមបានបញ្ចប់បេសកកម្មការទូតរបស់ខ្លួន អស់រយៈពេល៦ឆ្នាំ នៅកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះជោគជ័យដែលឯកឧត្តមឯកអគ្គរដ្ឋទូតបានបំពេញក្នុងអណត្តិរបស់ខ្លួន ក្នុងការលើកកម្ពស់និងជំរុញបន្ថែមកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជានិងសហព័ន្ធរុស្ស៊ី ឱ្យកាន់តែរីកចម្រើន និងសំបូរបែប។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអះអាងថា សមិទ្ធិផលជាក់ស្តែងជាច្រើន បានកើតចេញជារូបរាងក្រោមការខិតខំប្រឹងប្រែងនិងការរួមចំណែករបស់ឯកឧត្តមឯកអគ្គរដ្ឋទូត ជាក់ស្តែង មានកិច្ចព្រមព្រៀងចំនួន៥២ ដែលគ្រប់ដណ្តប់លើវិស័យផ្សេងៗដូចជា៖ ពាណិជ្ជកម្មនិងវិនិយោគ កសិកម្ម សុខាភិបាល អប់រំ កីឡា វប្បធម៌ ទេសចរណ៍ ព័ត៌មាន បរិស្ថាន សន្តិសុខ ការពារជាតិ និងយុត្តិធម៌ជាដើម ត្រូវបានចុះហត្ថលេខាក្នុងអាណត្តិរបស់ឯកឧត្តម។ មេដឹកនាំនៃប្រទេសទាំងពីរបានជួបគ្នាជាញឹកញាប់ពោលគឺ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាការងារជាមួយប្រធានាធិបតី **ពូទីន** និងនាយករដ្ឋមន្ត្រី **មេដវេដេវ** នៅទីក្រុងម៉ូស្គូ សូឈី ភ្នំពេញ និងនៅក្នុងឱកាសវេទិកាអន្តរជាតិ និងតំបន់នានា ឯ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបំពេញទស្សនកិច្ចការងារពីរលើកនៅម៉ូស្គូ ដឹកនាំកិច្ចប្រជុំគណៈកម្មការសហប្រតិបត្តិការអន្តររដ្ឋាភិបាលពីរលើកនៅភ្នំពេញ និងនៅម៉ូស្គូ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានមានប្រសាសន៍បន្ថែមថា ជារួមបេសកកម្មរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតកន្លងមកនេះ ចាត់ទុកថាជាជោគជ័យមួយក្នុងការនាំទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរទៅកម្រិតខ្ពស់មួយថែមទៀត។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងភាគីកម្ពុជាពាក់ព័ន្ធទាំងអស់ដែលបានផ្តល់នូវការគាំទ្រ និងសហការយ៉ាងជិតស្និទ្ធិដល់ឯកឧត្តម ក៏ដូចជាដល់ស្ថានទូតរុស្ស៊ីក្នុងអាណត្តិរបស់ខ្លួន។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានបញ្ជាក់ថា ជោគជ័យទាំងអំបាលមាណខាងលើអាចសម្រេចទៅបាន គឺពិតជាមានការចូលរួមពីសំណាក់ភាគីកម្ពុជាទាំងអស់។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងផងដែរថា បើទោះបីកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរបានរីកចម្រើនយ៉ាងនេះក៏ដោយ ក៏**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានមើលឃើញថា យើងមានវិស័យ

មួយចំនួនទៀត ដែលត្រូវពង្រឹងពង្រីកបន្ថែមទៀត ឧទាហរណ៍ ដូចជាទំហំនៃការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរនៅមានទំហំតូច និងទេសចរណរុស្ស៊ី ដែលមកទស្សនាកម្ពុជាមិនទាន់មានចំនួនធំនៅឡើយ។ ក្នុងន័យនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្នើឱ្យភាគីរុស្ស៊ីជួយពន្លឿនការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងកម្ពុជាជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី (EAEU) ផងដែរ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានឯកភាពជាមួយការលើកឡើងរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងបានអះអាងថា បើអ្វីៗដំណើរការដូចតាមផែនការ នោះនៅដាច់ឆ្នាំ២០២០នេះ នឹងមានជើងហោះហើរត្រង់ពីរុស្ស៊ីមកកម្ពុជា ដែលកត្តានេះនឹងជួយជំរុញទេសចរ ក៏ដូចជាពាណិជ្ជកម្ម រវាងប្រទេសទាំងពីរ។ ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី ឯកឧត្តមឯកអគ្គរដ្ឋទូត បានបញ្ជាក់ថា រុស្ស៊ីគាំទ្រ និងជួយជំរុញពេញទំហឹងលើការងារនេះ។ ជាមួយគ្នានេះផងដែរ ដើម្បីចូលរួមចំណែកជាមួយកម្ពុជាក្នុងបុព្វហេតុមនុស្សជាតិ ដើម្បីប្រយុទ្ធប្រឆាំងកូវីដ១៩ រុស្ស៊ីកំពុងពិភាក្សាជាមួយក្រសួងសុខាភិបាលកម្ពុជា ក្នុងការជួយជាថ្នាំពេទ្យ និងបរិក្ខាផ្សេងៗដល់កម្ពុជា។

ជាចុងបញ្ចប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះកាយវិការសប្បុរសធម៌របស់រុស្ស៊ី ដែលជួយកម្ពុជាក្នុងគ្រាលំបាកនេះ ហើយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជូនពរឯកឧត្តមឯកអគ្គរដ្ឋទូតឱ្យទទួលបានជោគជ័យក្នុងភារកិច្ចខាងមុខ ព្រមទាំងសន្យានឹងផ្តល់កិច្ចសហការ និងគាំទ្រដល់ឯកអគ្គរដ្ឋទូតថ្មី ដែលនឹងចូលកាន់តំណែងក្នុងពេលឆាប់ៗខាងមុខនេះ៕